ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៤ លេខ ០៨

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក ស វ

# Work Activities

ប្រចាំខែសីហា ឆ្នាំ២០១១



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការផ្ដល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម | ១ |
| ២- | កិច្ចប្រជុំបន្តលើសេចក្ដីព្រាងច្បាប់ស្ដីពីកិច្ចសន្យាពាណិជ្ជកម្ម | ២ |
| ៣- | ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆមាសទី១ ឆ្នាំ២០១១ | ៣ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១០ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម

កាលពីថ្ងៃទី១០ និងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង៨:៣០នាទី និងម៉ោង១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុំ ម៉ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានតាក់តែងសេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម ដែលមានគោលដៅកំណត់អំពីយន្តការ នីតិវិធី និងលក្ខខណ្ឌនៃការជ្រើសរើស និងការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម និងមានគោលបំណងលើកកម្ពស់គុណភាពបណ្តុះបណ្តាលនៅគ្រឹះស្ថានឧត្តមសិក្សាក្នុងវិស័យកសិកម្ម លើកតម្កើងកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់សាស្ត្រាចារ្យក្នុងវិស័យកសិកម្ម លើកកម្ពស់ការទទួលខុសត្រូវនិងគុណវុឌ្ឍិរបស់សាស្ត្រាចារ្យក្នុងវិស័យកសិកម្ម ចូលរួមចំណែករៀបចំនិងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្មឲ្យមានគុណភាពនិងប្រសិទ្ធភាពខ្ពស់។

សេចក្តីព្រាងនេះកំណត់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្មរួមមាន៖ សាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ។

បច្ចុប្បន្ននេះ វិស័យកសិកម្មមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីចូលរួមចំណែកលើកកម្ពស់ការអភិវឌ្ឍកសិកម្មជាតិឲ្យកាន់តែមានការរីកចម្រើនឈានឡើងជាលំដាប់ស្របទៅនឹងអនុសាសន៍ដ៏ថ្លៃថ្លារបស់ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា ដែលតែងតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាពមួយនៅគ្រប់កាលៈទេសៈ។

ជាបទពិសោធន៍ កាលៈទេសៈបច្ចុប្បន្ន សាកលវិទ្យាល័យនានានៅគ្រប់ប្រទេស ជាពិសេសប្រទេសជិតខាងយើង មន្ត្រីសាស្ត្រាចារ្យដែលបម្រើការងារបង្រៀន ស្រាវជ្រាវ និងមន្ត្រីរដ្ឋបាលខ្លះត្រូវបានរដ្ឋាភិបាល និងសាកលវិទ្យាល័យយកចិត្តទុកដាក់ជំរុញការលើកទឹកចិត្តតាមរយៈការបង្កើតឲ្យមានក្របខណ្ឌគ្រូបង្រៀននៅតាមសាកលវិទ្យាល័យ ដើម្បីធានាគុណភាពអប់រំ តាមវិស័យនីមួយៗឲ្យបានល្អប្រសើរ។ ការបង្កើតក្របខណ្ឌនេះ គឺជាយន្តការមួយល្អពិសេសដើម្បីផ្តល់កម្លាំងចិត្តដល់មន្ត្រីសាស្ត្រាចារ្យឲ្យកាន់តែខិតខំលើកកម្ពស់សមត្ថភាពខ្លួនថែមទៀត។ ការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម ពុំទាន់មាននៅឡើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា[១]។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង៕

---

[១] អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម។

## កិច្ចប្រជុំបន្តលើសេចក្តីព្រាងច្បាប់ស្តីពី

# កិច្ចសន្យាពាណិជ្ជកម្ម

ឯកឧត្តម **ម៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ឌីម សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ បានរួមគ្នាដឹកនាំអង្គប្រជុំជំនាញបច្ចេកទេស ចំនួន១៦លើកក្នុងខែសីហា ឆ្នាំ២០១១នេះ ដើម្បីពិនិត្យពិភាក្សាបន្តលើ**សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងពាណិជ្ជកម្ម។

សូមរំឭកថា សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម បានឆ្លងអង្គជំនាញបច្ចេកទេសជាច្រើនលើក ហើយបានសម្រេចដល់ជំពូកទី១១ ស្តីពីកិច្ចសន្យាដឹកជញ្ជូនដែលអង្គប្រជុំមិនអាចបន្តពិភាក្សាបាន ពីព្រោះមានបញ្ហាច្រើនត្រូវកែសម្រួល។ អង្គប្រជុំនាពេលនោះបានសម្រេចបង្កើតក្រុមការងារចង្អៀតមួយមានសមាសភាព ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងសាមីក្រសួង ដើម្បីជួយពិនិត្យកែសម្រួលខ្លឹមសារនៃជំពូកទី១១ស្តីពីកិច្ចសន្យាដឹកជញ្ជូននេះឡើងវិញ មុននឹងយកមកដាក់ប្រជុំជំនាញបច្ចេកទេសនៅពេលក្រោយទៀត។





អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាបន្តលើជំពូកទី១១ ស្តីពីកិច្ចសន្យាដឹកជញ្ជូនកែសម្រួលថ្មីដែលមាន ៥៤ មាត្រា ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង៕

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកក្កដា ឆ្នាំ២០១១*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកក្កដា ឆ្នាំ២០១១នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០១១ ដែលដឹកនាំដោយ ឯកឧត្តម **យឹម ឆាយលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែកក្កដានេះសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើង ០,៦% ធៀបនឹងខែមុន និងកើនឡើង ៧,១% បើធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល ១២ខែ)។ កត្តានៃកំណើនសន្ទស្សន៍ថ្លៃខែ **កក្កដា/មិថុនា** គឺក្រុមម្ហូបអាហារ ដែលរួមចំណែក ៧០% និងក្រុមដឹកជញ្ជូន ដែលរួមចំណែក ៣១% ទៅលើសន្ទស្សន៍ថ្លៃសរុប។

➡ ក្រុមទំនិញដែលគួរឲ្យចាប់អារម្មណ៍ មានបម្រែបម្រួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖

| ប្រភេទ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ | ប្រភេទ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|---|---|
| ម្ហូបអាហារ | +០,៩% | +៨,៩% | ភោជនីយដ្ឋាន | +០,៦% | +១១% |
| ការដឹកជញ្ជូន | +១,៤% | +៨,៩% | | | |

➡ គួរកត់សម្គាល់ថា នៅក្នុងក្រុមម្ហូបអាហារ ថ្លៃសាច់ជ្រូក និងត្រីស្រស់ មានការកើនឡើងខ្ពស់៖ ៥,១% និង ២,៦% រៀងគ្នា ធៀបនឹងខែមុន និងបើធៀបនឹងខែដូចគ្នាឆ្នាំមុន កើនឡើង ២១% និង ១៤% រៀងគ្នា។ ទំនិញពីរមុខនេះ រួមចំណែក ៨៥% ទៅលើសន្ទស្សន៍ថ្លៃសរុបនៃខែ **កក្កដា/មិថុនា**។

* ការវិភាគជាលាយលក្ខអក្សរជាការដកស្រង់ចេញពីទិន្នន័យចម្បងៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់នៃតារាងទាំង៥ទេ។ ដូច្នេះអ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរៀងខ្លួន។
* ព័ត៌មាន និងតួលេខពណ៌ **បៃតង** សំដៅលទ្ធផលល្អប្រសើរ និងពណ៌ **ក្រហម** សំដៅលទ្ធផលសម្រាប់ការថ្លឹងថ្លែង
* ដើម្បីមានសង្គតិភាពជាមួយក្រុមភាសាខ្មែរ សញ្ញាក្បៀសនៅក្នុងសំណេរតាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (ជា Excel) សញ្ញាក្បៀសជាកំណាត់ខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

### តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០០៩-២០១១

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា P | កញ្ញា P | តុលា P | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ P |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១ | ៧,៦ | ៧,៦ | ៧,៥ | | | ៦,៦% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦ | ០,៦ | ០,៥ | -០,២ | | | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| | ខែមុន | 0% | ០,៣% | ០,៦% | -០,៣% | ០,២% | 0% | ០,៥% | ០,៩% | ០,៧% | ១,៤% | –១,០% | –០,២% | |
| ២០០៩ | ខែដូចគ្នាឆ្នាំមុន | ៨,០% | ៦,២% | -០,៧% | -៣,៩% | -៥,៧% | -៤,៨% | -៣,៩% | -២,៩% | -២,៣% | -១,៥% | ១,៣% | ៨,០% | -០,៧% |
| | ខែមុន | -១,៥% | -០,១% | ១,៣% | ១,០% | ១,០% | ១,៩% | ១,៤% | ០,៧% | ០,៥% | -០,៣% | -០,៦% | -០,១% | |

P: តួលេខខែសីហា កញ្ញា តុលា និងប្រចាំឆ្នាំ២០១១ ជាតួលេខព្យាកររបស់ ក.ស.វ. (តាមវិធីសាស្រ្ត DECOMPOSITION)

### ក្រាហ្វ ១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ឆ្នាំ២០១០ និងឆ្នាំ២០១១ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)




ក្រាហ្វ១ បង្ហាញនិន្នាការបម្រែបម្រួលសន្ទស្សន៍ថ្លៃ (ធៀបនឹងខែដូចគ្នា) ឆ្នាំ២០១០ និងឆ្នាំ២០១១។ ក្រាហ្វក៏បង្ហាញផងដែរ នូវតួលេខការព្យាករបីខែទៅមុខនៃអតិផរណា (ធៀបនឹងខែដូចគ្នាឆ្នាំមុន) ។

➡ **អត្រាប្តូរប្រាក់៖**

| *ប្រភេទ* | អត្រា ខែកក្កដា | *%Δ ធៀបនឹង ខែមុន* | *%Δ រយៈពេល ១២ខែ* | *ប្រភេទ* | អត្រា ខែកក្កដា | *%Δ ធៀបនឹង ខែមុន* | *%Δ រយៈពេល ១២ខែ* |
|---|---|---|---|---|---|---|---|
| រ/ដុល្លារ | ៤ ១០០រ/១ដុល្លារ | –០,៤% | –៣,២% | បាត/ដុល្លារ | ២៩,៧បាត/១ដុល្លារ | –៣,៤% | –៧,៨% |
| រ/បាត | ១៣៨រ/១បាត | +៣,០% | +៥,៣% | ដុង/ដុល្លារ | ២០ ៥២០ដុង/ដុល្លារ | –0.២% | +៧,៦% |
| រ/ដុង | ០,១៩៨រ/១ដុង | –១% | –១០,៨% | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡ យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ **នាខែកក្កដា ឆ្នាំ២០១១ ថវិកាជាតិ**មានស្ថានភាពដូចខាងក្រោម៖

- ***ចំណូលអនុវត្តបានចំនួន ៥១០,៤ ពាន់លានរៀល*** *(មធ្យមប្រចាំខែ៩១% នៃគម្រោង)* *ក្នុងនោះ* ***ចំណូលមូលធន ១,៨ ពាន់លានរៀល*** *(មធ្យមប្រចាំខែ ១០៦% នៃគម្រោង)* និង **ចំណូលចរន្ត ៥០៨,៧ ពាន់លានរៀល** (មធ្យមប្រចាំខែ ៩០% នៃគម្រោង)។

- បើធៀបនឹងខែមុន**ចំណូលថវិកាជាតិ** កើនឡើង ១៤% ប៉ុន្តែ**ថយចុះ ៣%** ក្នុងរយៈពេល ១២ខែ។ ការកើនឡើងនៃចំណូលក្នុងខែនេះ ជាចំបងបណ្តាលមកពីចំណូលចរន្តកើនឡើង ១៤% ប៉ុន្តែបើធៀបនឹងខែដូចគ្នាឆ្នាំមុនចំណូលចរន្ត**ថយចុះ ១%** ។

### ក្រាហ្វ ២. ចំណូលថវិកាជាតិ ២០១០–២០១១



- នៅក្នុងចំណូលចរន្ត៖
  - ✓ ចំណូលសារពើពន្ធកើនឡើង ១២% បើធៀបនឹងខែមុន និងកើនឡើង ២% ក្នុងរយៈពេល ១២ខែ។ ការកើនឡើងនៃចំណូលសារពើពន្ធធៀបនឹងខែមុន បណ្តាលមកពី ពន្ធ-អាករគយ កើនឡើង ៣% និងចំណូលពន្ធដារ កើនឡើង ១១% ។ គួរចាប់អារម្មណ៍ថា ចំណូលពន្ធដារ ***ថយចុះ ១១%*** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

| **ក្នុងចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក៖ បម្រែបម្រួលរយៈពេល ១២ខែ) | | **ក្នុងចំណូលមិនមែនសារពើពន្ធ** (ក្នុងវង់ក្រចក៖ បម្រែបម្រួលរយៈពេល ១២ខែ) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +៣% | ( +១៣%) | ➢ នេសាទ : -៣២% | (+៥៧%) |
| ➢ ចំណូលពន្ធដារ: +១១% | (-១១%) | ➢ រុក្ខាប្រមាញ់ : +២០២% | (-២៦%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ: -៤១% | ( –១៥%) | ➢សម្បទានរ៉ែ : +៦៣% | (+៣៧%) |
| | | ➢ អាកាសចរណ៍ស៊ីវិល : -៥២% | (-៤១%) |
| | | ➢ ផលទុនទេសចរណ៍ : -៥៩% | (+១៥%) |
| | | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : -៤៨% | (-៥៤%) |
| | | ➢ អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ) : +៦៤% | (+៤៦%) |
| | | ➢ ចំណូលផ្សេងទៀតពុំមែនសារពើពន្ធ : +១០៦% | (+៧៤%) |

  - ✓ គួរកត់សម្គាល់លើការថយចុះនៃចំណូលសារពើពន្ធផ្សេងៗ ជាពិសេសចំណូលពីកាស៊ីណូ **ថយចុះ** ៧៨% ធៀបនឹងខែមុន និង**ថយចុះ** ៤៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
  - ✓ ចំណូលមិនមែនសារពើពន្ធកើនឡើង ២៤% បើធៀបនឹងខែមុន ប៉ុន្តែថយចុះ ១៧% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ គួរកត់សម្គាល់លើការថយចុះធៀបនឹងខែដូចគ្នាឆ្នាំមុន នៃខ្ទង់ចំណូលមួយចំនួនដូចជា អាកាសចរណ៍ស៊ីវិល ថយចុះ ៤១% និងប្រៃសណីយ៍ និងទូរគមនាគមន៍ ថយចុះ ៥៤% ។

- ***ចំណាយថវិកាជាតិ*** អនុវត្តបាន ៥០១ ពាន់លានរៀល (*មធ្យមប្រចាំខែ ៦១% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៣៩១ ពាន់លានរៀល(*មធ្យមប្រចាំខែ ៩១% នៃគម្រោង*) និង**ចំណាយមូលធន**មានចំនួន ១១០ ពាន់លានរៀល(*មធ្យមប្រចាំខែ ២៣% នៃគម្រោង*) ។
- *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** *ថយចុះ ៣០%* និង***ថយចុះ ២១%*** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការថយចុះនៃចំណាយថវិកាជាតិក្នុងខែនេះ បណ្តាលមកពីចំណាយចរន្ត***ថយចុះ ៣៦%*** និងបើធៀបនឹងខែដូចគ្នាឆ្នាំមុន ចំណាយចរន្ត***ថយចុះ ២៥%*** ។
- ***តុល្យភាពថវិកាជាតិនៃខែកក្កដាមានអតិរេក ៩ ពាន់លានរៀល*** ។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ ស្ថានភាពរូបិយវត្ថុ ក្នុងខែកក្កដា ឆ្នាំ២០១១ មានលក្ខណៈដូចខាងក្រោម៖

- **កំណើន $M_2$** ធៀបនឹងខែមុន បណ្តាលមកពីប្រាក់បញ្ញើជារូបិយបណ្ណ កើនឡើង ២,១% ( រយៈពេល ១២ខែ : +២២%) និងប្រាក់បញ្ញើមានកាល កំណត់ និងសន្សំ កើនឡើង ៦,៥% ( រយៈពេល ១២ខែ : +១៨% )។
- យោងតាមតួលេខសមាសធាតុរូបិយវត្ថុ ក្នុងខែកក្កដា ប្រាក់រៀល**ក្នុងសេដ្ឋកិច្ច**មានចំនួន ១៧,៦% នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណ មានចំនួន ៨២,៤%។

**ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុ ខែកក្កដា ២០១១**



សមាមាត្រ រវាងចំនួនប្រាក់រៀល និងការផ្គត់ផ្គង់រូបិយវត្ថុ $M_2$

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុង និងក្រៅធនាគារ | ១៨,៣% | ១៩,១% | ១៩,២% | ១៩,១% | ១៨,៥% | ១៨,០% | ១៧,៦% | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៥,៧% | ១៦,០% | ១៦,៧% | ១៦,៦% | ១៥,៧% | ១៥,២% | ១៤,៩% | | | | | |

## បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែកក្កដា ២០១១ ៖ ក្នុងវង់ក្រចកជា បម្រែបម្រួលរយៈពេល ១២ខែ




➣**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន **២ ៨៣០ លានដុល្លារ** កើនឡើង ១,២% បើធៀបនឹងខែមុន និងកើនឡើង ២០%ក្នុងរយៈពេល ១២ខែ។

➣ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** មានចំនួន **៧ ៨៩៦ ពាន់លានរៀល**កើនឡើង ២,៣% បើធៀបនឹងខែមុន និងកើនឡើង ៨% ក្នុងរយៈពេល ១២ខែ។

➣***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ*** មានចំនួន ១៥ ៤៤៧ ពាន់លានរៀល កើនឡើង ០,៧% បើធៀបនឹងខែមុន និងកើនឡើង ២៧% ក្នុងរយៈពេល ១២ខែ។

➣***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** មាននិន្នាការកើនឡើងជាលំដាប់។ ដោយឡែក ក្នុងខែកក្កដានេះ មានចំនួន ២ ១៤០ ពាន់លានរៀល កើនឡើង ៣,៨% បើធៀបនឹងខែមុន និងកើនឡើង ៤៨% ក្នុងរយៈពេល ១២ខែ។

➣***អត្រាការប្រាក់ប្រចាំឆ្នាំ*** :

| *ប្រភេទអត្រាការប្រាក់* | *អត្រា* | *%Δ ធៀបនឹងខែមុន* | *%Δ រយៈពេល១២ខែ* |
|---|---|---|---|
| ▪ បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៥២% | ០,២% | –១% |
| ▪ កម្ចីជារៀលនៅធនាគារពាណិជ្ជ | ២២,៤១% | -០,២% | –២% |
| ▪ បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៣៥% | -០,៥% | –៤% |
| ▪ កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១៦,៧២% | -០,៦% | +៤% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ ក្នុងខែកក្កដា ឆ្នាំ២០១១ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➣ **កសិកម្ម៖**

✓ផលិតកម្មនេសាទមាន **៣៧ពាន់តោន** ថយចុះ៤៨% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៦% ក្នុងរយៈពេល ១២ខែ។

### ឧស្សាហកម្ម៖

✓ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២២៦ លានគីឡូវ៉ាត់ម៉ោង កើនឡើង ២% បើធៀបនឹងខែមុន និងកើនឡើង ១៥% ក្នុងរយៈពេល ១២ខែ។

✓អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ៣ លានគីឡូវ៉ាត់ម៉ោង កើនឡើង២០% បើធៀបនឹងខែមុននិងកើនឡើង២១៩% ក្នុងរយៈពេល ១២ខែ។

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៣៩២ លានដុល្លារ កើនឡើង២១% បើធៀបនឹងខែមុន និងកើនឡើង ១៥% ក្នុងរយៈពេល ១២ខែ។

✓ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស៖

| *ប្រភេទ* | *ចំនួន —កក្កដា២០១១* | *ចំនួន—មិថុនា២០១១* | *ចំនួន—កក្កដា២០១០* |
|---|---|---|---|
| ▪ រោងចក្រថ្មី ដែលបានចុះបញ្ជី | ៨ | ១២ | ៥ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៧ | ២៧ | ៣ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១៨ | ៣៣ | ១១ |

### សំណង់៖

✓ **សំណង់អនុញ្ញាតឲ្យសាងសង់**ក្នុងខែកក្កដា មានចំនួន ៣៨៦ ពាន់ម² ថយចុះ ១០% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង៧២% ក្នុងរយៈពេល ១២ខែ។ បើគិតជាទឹកប្រាក់ ការអនុញ្ញាតឲ្យសាងសង់មានតម្លៃ ១១០ លានដុល្លារ ថយចុះ១៧% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៤៣% ក្នុងរយៈពេល ១២ខែ។

✓ **សំណង់ដែលពេញនិយម** យោងតាមតួលេខអនុញ្ញាតនាខែនេះ គឺលំនៅឋាន (៧០% នៃផ្ទៃក្រឡាអនុញ្ញាតសរុប)។

| *ប្រភេទ* | *ផ្ទៃក្រលា ពាន់ម² —កក្កដា២០១១* | *%Δ ធៀបនឹងខែមុន* | *%Δ រយៈពេល១២ខែ* |
|---|---|---|---|
| ▪ លំនៅឋាន | ២៧១ | +២១៦% | +៣១៥% |
| ▪ ឧស្សាហកម្ម | ៧៧ | -៣០% | +៣០៦% |
| ▪ ពាណិជ្ជកម្ម | ៦ | -៩៧ | -៩១ |
| ▪ ទេសចរណ៍ | ១៦ | -៥៧% | -៥១% |

### ការងារ៖

| *ប្រភេទ* | *ចំនួន—កក្កដា២០១១* | *%Δ ធៀបនឹងខែមុន* | *%Δ រយៈពេល១២ខែ* |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ២ ១៨៤ | –១% | –៤៥% |
| *អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន* | ២ ៥៤៥ | +៣៤% | -៦៤% |
| អ្នកទទួលបានការងារក្នុងប្រទេស | ៧៧៩ | +៧២% | -៥១% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១ ៧៦៦ | +២២% | -៦៨% |

### វិនិយោគ៖

✓ គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./គ.អ.ក. (ថ្មី និងពង្រីក) ក្នុងខែកក្កដាមានចំនួន **២១** ដែលគិតជាទុន វិនិយោគស្មើនឹង **២ ៦៥០ លានដុល្លារ** ។ គម្រោងទាំងនេះ អាចបង្កើតការងារឲ្យពលករបាន **១៩ ពាន់នាក់**។

| *ប្រភេទ* | *កក្កដា២០១១* | *មិថុនា២០១១* | *កក្កដា២០១០* |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ២ ៦៥០ | ២៥៩២ | ១១៩ |
| វិស័យកសិកម្ម និង កសិឧស្សាហកម្ម | ១៥៧ | ១៥៦ | ២ |
| វិស័យឧស្សាហកម្ម | ២ ២៨៦ | ៧៣ | ១១៧ |
| វិស័យទេសចរណ៍ | ២០៦ | ៥១ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធ និង ផ្សេងៗ | ២ | ២៣១៣ | ០ |
| **ចំនួនគម្រោងថ្មីនិងពង្រីក (ចំនួន)** | ២១ | ២២ | ១០ |
| **ចំនួនពលករ (ពាន់នាក់)** | ១៩ | ៣៣ | ១៥ |

### សេវាកម្ម និងទេសចរណ៍៖

✓**ការចុះបញ្ជី និងលុបចេញពីបញ្ជី**

| ប្រភេទ | ចំនួន–កក្កដា២០១១ | ចំនួន–មិថុនា២០១១ | ចំនួន–កក្កដា២០១០ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៩៣ | ២៦១ | ២៥៨ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៥ | ២ | ០ |
| ▪ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៣០៨ | ៣០២ | ២៤៨ |

✓ **ទំនិញឆ្លងកាត់កំពង់ផែ** (សរុប ៦កំពង់ផែ) មានចំនួន ៤៥១ ពាន់តោន កើនឡើង ១៤%ធៀបនឹងខែមុន និងកើនឡើង ៣៦%ក្នុងរយៈពេល ១២ខែ។ ក្នុងនោះ៖

| ក្នុងវង់ក្រចក: បម្រែបម្រួលក្នុងរយៈពេល១២ខែ | | | |
|---|---|---|---|
| ▪ ផែភ្នំពេញ : –១% | (+២២%) | ▪ ផែស្រែអំបិល និងកោះកុង : +៤០% | (+៣០១៥%) |
| ▪ ផែកំពង់សោម : +១៨% | (+១២%) | ▪ ផែឧកញ៉ាម៉ុង : -៤៣% | (-២៩%) |

### ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|
| ▪ ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៥ | +១០០% | +៤% |
| ▪ អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | N/A | N/A | N/A |
| ▪ ចំនួនអ្នកទេសចរជាតិចេញក្រៅប្រទេស | ៦៤ | +២៦% | +៤៥% |
| ▪ ចំនួនអ្នកទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | ២៤០ | +២៤% | +១៨% |
| ✓ តាមផ្លូវអាកាស | ១១៥ | +២៨% | +១៨% |
| ✓ តាមផ្លូវគោក និងទឹក | ១២៣ | +១៩% | +១៨% |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**នាខែកក្កដាមានចំនួន ២ ១៨០ ពាន់លានរៀល បើធៀបនឹងខែមុន ថយចុះ ៥% ប៉ុន្តែកើនឡើង ៦% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះ៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δ១២ខែ |
|---|---|---|
| ប្រេងសាំង | –0,៥% | –៧% |
| ប្រេងម៉ាស៊ូត | +១% | +២៦% |
| ប្រេងខ្មៅ | +១២% | –១០% |
| អគ្គិសនី | +៤% | +១៦% |
| ដែកសំណង់ | +៧៥% | –១៤% |
| រថយន្តសរុប (ព.ល.រ) | +១២% | +៤% |
| រថយន្តសរុប (គ្រឿង) | +៣០% | +១៣% |

| ទំនិញ | %Δធៀបនឹងខែមុន | %Δ១២ខែ |
|---|---|---|
| ឧស្ម័ន | –៣៥% | –២% |
| ស៊ីម៉ង់ត៍ | –១២% | +៣% |
| គ្រឿងអេឡិចត្រូនិក | –២៦% | –១% |
| ត្រាក់ទ័រនិងគោយន្ត | –៣៥% | +៣០% |
| ម៉ូតូ | –២៤% | +៧២% |
| ជីនិងថ្នាំកសិកម្ម | –២០% | +៤១% |
| នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | –១១% | +១១% |

➡ **ការនាំចេញ៖** ក្នុងខែកក្កដា ឆ្នាំ២០១១ មានចំនួន ២ ១៦៨ ពាន់លានរៀល (៩៩% នៃការនាំចូល) កើនឡើង ២០% ធៀបនឹងខែមុន និងកើនឡើង ៣១% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះ មុខទំនិញសំខាន់ៗមួយចំនួនមាន៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δ ១២ខែ | ទំនិញ | %Δធៀបនឹងខែមុន | %Δ ១២ខែ |
|---|---|---|---|---|---|
| វាយនភណ្ឌនិងស្បែកជើង | +២៧% | +២៨% | ផលិតផលឈើកែច្នៃ | –៩៥% | –៩៣% |
| កៅស៊ូ | +៥៣% | +១១២% | អង្ករ | –២៩% | +១៩០% |
| ផលិតផលនេសាទ | +៦៥% | +៦៩% | | | |

➡ ក្នុងខែកក្កដា ឆ្នាំ២០១១នេះ ជញ្ជីងពាណិជ្ជកម្មកម្ពុជាមាន *ឱនភាពចំនួន ១២ ពាន់លានរៀល ស្មើនឹង ២,៩ លានដុល្លារ ស.រ.អ.។*

## ៦) ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកក្កដា ឆ្នាំ២០១១នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | រយៈពេល១២ខែ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃសាច់ជ្រូក<br>ថ្លៃសាច់គោស្រស់<br>ថ្លៃត្រីស្រស់ | +៥,១%<br>+២,០%<br>+១៣% | +២១%<br>+១៣%<br>+១៤% | អត្រាអតិផរណានៅកម្ពុជា ជារួមដោយគឺសារ ការឡើងថ្លៃ នៃក្រុមសាច់។ សាច់ទាំងបីមុខនេះ រួមចំណែក ៩៣% ទៅលើអត្រាអតិផរណាសរុប ក្នុងខែកក្កដា។ |
| ២ | ពន្ធលើប្រាក់ចំណេញ | +១២% | *–៣៦%* | — |
| | ចំណូលពីកាស៊ីណូ | *–៧៨%* | *–៤៨%* | — |
| ៣ | វិនិយោគអនុញ្ញាតដោយ ក.អ.ក. / គ.វ.ក. (ទុនវិនិយោគ) | +២% | +២ ១២២% | ទុនវិនិយោគ ដែលអនុញ្ញាតដោយ ក.អ.ក. / គ.វ.ក. ក្នុងខែនេះមាន ២ ៦៥០ លានដុល្លារ ។ ប៉ុន្តែក្នុងចំនួននេះ មានតែ ៤២៨,៦ លានដុល្លារប៉ុណ្ណោះដែលអាចអនុវត្តបាន ក្រៅពីនោះមានតែការលើកតួលេខប៉ុណ្ណោះ ដែលជាគម្រោងកំពុងស្វែងរកដៃគូរអភិវឌ្ឍន៍។ |
| ៤ | ការនាំចេញកៅស៊ូ | +៥៣% | +១១២% | — |

## ៧) ស្មារតីអង្គប្រជុំ និងសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

ការជំរុញការចិញ្ចឹមសត្វ ជាកិច្ចការចំបងមួយក្នុងវិស័យកសិកម្ម។ ក្នុងពេលបច្ចុប្បន្ន វិស័យនេះមិនអាចផ្គាប់តម្រូវការក្នុងស្រុកដែលចេះតែកើនឡើងបានទេ។

ការនេះធ្វើឲ្យសេដ្ឋកិច្ចកម្ពុជា មានការពឹងផ្អែកលើការនាំចូលជាខ្លាំង ហើយអតិផរណាក្នុងប្រទេសជិតខាងក៏ជះឥទ្ធិពលលើការឡើងថ្លៃមុខទំនិញដែលកម្ពុជានាំចូល ដូចជា សាច់ បន្លែ ផ្លែឈើ ទំនិញប្រើប្រាស់ផ្សេងៗទៀត ។

***ក.ស.វ. មានសេចក្តីសន្និដ្ឋានដូចខាងក្រោម៖:***

ដើម្បីជំរុញវិស័យចិញ្ចឹមសត្វឲ្យមានការអភិវឌ្ឍឡើង គួរបង្កើនការយកចិត្តទុកដាក់លើវិស័យនេះ ដែលក្នុងនោះមានដូចជា ការជំរុញ និងលើកទឹកចិត្តចំពោះវិនិយោគឯកជនទ្រង់ទ្រាយធំ បើកទូលាយការផ្តល់ឥណទាន ការបណ្តុះបណ្តាល និងការបង្កើតរចនាសម្ព័ន្ធទីផ្សារជាដើម។

វិធានការដ៏សំខាន់មួយទៀត គឺការប្រើប្រាស់គោលនយោបាយសារពើពន្ធ តាមរយៈចំណាយចរិកាជាតិ ជាការឧបត្ថម្ភធន ដើម្បីជួយឲ្យវិស័យចិញ្ចឹមសត្វ រីកលូតលាស់ ឈានទៅរកការកាត់បន្ថយការឡើងថ្លៃសាច់ និងប្រែក្លាយកម្ពុជា ជាប្រទេសនាំចេញផលិតផលសាច់ដ៏សំខាន់មួយ។l

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៨/១១<br>ម៉ោង ០៨ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆមាសទី១ ឆ្នាំ២០១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | ០១/០៨/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួលការអនុវត្តគម្រោងវិនិយោគសាងសង់សារមន្ទីរសព្វទស្សន៍ ( Panorama Museum ) ក្នុងខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ០២/០៨/១១<br>ម៉ោង ០៨ : ៣០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីពន្ធនាគារ ។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការជ្រើសរើសចូលក្របខណ្ឌ ការប្រឡងផ្លាស់ប្តូរប្រភេទក្របខណ្ឌ ការតម្លើងឋានន្តរសក្តិ និងការតម្លើងថ្នាក់មន្ត្រីរាជការស៊ីវិល ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៤ | ០២/០៨/១១<br>ម៉ោង ១៦ : ៣០ នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីពន្ធនាគារ ។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការជ្រើសរើសចូលក្របខណ្ឌ ការប្រឡងផ្លាស់ប្តូរប្រភេទក្របខណ្ឌ ការតម្លើងឋានន្តរសក្តិ និងការតម្លើងថ្នាក់មន្ត្រីរាជការស៊ីវិល ។<br>៣-បញ្ហាផ្សេងៗ ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៥ | ០៣/០៨/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយគណៈកម្មការព្រលានយន្តហោះ ស្តីពីការពិនិត្យកែលំអក្លោងទ្វារច្រកចូល VIP (ប៉ុស្តិ៍ A) នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅបន្ទប់ឯកឧត្តមប្រធាន ECOSOCC នៃទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៦ | ០៤/០៨/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំក្រុមការងារស្តីពី Technical Cooperation រវាងភាគីកម្ពុជា និងភាគីចិន នៅបន្ទប់ឯកឧត្តមប្រធាន ECOSOCC នៃទីស្តីការគណៈរដ្ឋមន្ត្រី ។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១១ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ០៥/០៨/១១<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ ។<br>៣-បញ្ហាផ្សេងៗ ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ៨ | ០៨/០៨/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការជ្រើសរើសចូលក្របខណ្ឌ ការប្រឡងផ្លាស់ប្តូរប្រភេទក្របខណ្ឌ ការតម្លើងឋានន្តរសក្តិ និងការតម្លើងថ្នាក់មន្ត្រីរាជការស៊ីវិល ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់តំបន់សហគមន៍លើផ្ទៃដីទំហំ ១៥០០ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៩ | ១១/០៨/១១<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្ររង ដល់និស្សិតសាកលវិទ្យាល័យធនធានមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១០ | ១២/០៨/១១<br>ម៉ោង ០៩ : ០០ នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួលការអនុវត្តគម្រោងវិនិយោគសាងសង់សារមន្ទីរសព្វទស្សន៍ ( Panorama Museum ) ក្នុងខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១១ | ១៥/០៨/១១<br>ម៉ោង ១០ : ០០ នាទី | ដឹកនាំក្រុមការងារចុះត្រួតពិនិត្យបញ្ចប់លើការងារជួសជុលកែលំអផ្លូវ ៣០ម ប្រវែង ១.៥០០ម ខាងមុខអង្គការវ៉ាក់ និងជួសជុលស្នាផ្លូវហ្សាដឺហ្វាលទទឹង ២ម ប្រវែង ២.៥០០ម ខេត្តសៀមរាប នៅទីស្នាក់ការអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា ខេត្តសៀមរាប ។ |
| ១២ | ១៦/០៨/១១<br>ម៉ោង ០៨ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការកំណាត់ផ្លូវជាតិលេខ ១ ប្រវែង ៩.១០គ.ម ពី គ.ម ៤+០០០ (ក្តីតាកុយ) ដល់ គ.ម ១៣+១០០ (ផ្សារគគីរ) គម្រោងដំណាក់កាលទី៣ ក្រោមកម្មវិធីជំនួយឥតសំណងរបស់ប្រទេសជប៉ុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅភូមិទួលតាចាន់ សង្កាត់ព្រែកឯង ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ |
| ១៣ | ១៧/០៨/១១<br>ម៉ោង ០៩ : ០០ នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ CEO ក្រុមហ៊ុន SCA នៅបន្ទប់ឯកឧត្តមប្រធាន ECOSOCC នៃទីស្តីការគណៈរដ្ឋមន្ត្រី ។ |

# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១១ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៤ | ១៨/០៨/១១<br>ម៉ោង ១៥ : ៣០ នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។ |
| ១៥ | ១៩/០៨/១១<br>ម៉ោង ១៧ : ៣០នាទី | ធ្វើបទបង្ហាញជូន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អំពីគម្រោងវិនិយោគសាងសង់សារមន្ទីរសព្វទស្សន៍ (Panorama Museum) ក្នុងខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៦ | ២២/០៨/១១<br>ម៉ោង ១១ : ០០ នាទី | ជួបប្រជុំពិភាក្សាលើកិច្ចព្រមព្រៀងវិនិយោគរវាងភាគីកម្ពុជា និងភាគីវៀតណាម នៅបន្ទប់ឯកឧត្តមប្រធាន ECOSOCC នៃទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៧ | ២៤/០៨/១១<br>ម៉ោង ០៧ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសន្និបាតបូកសរុបការងាររណសិរ្ស លើកទី៤ និងលើកទិសដៅសម្រាប់អនុវត្តឆ្នាំបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាពញាចក្រីកិត្តិព្រឹទ្ធបណ្ឌិត **ហេង សំរិន** ប្រធានរដ្ឋសភា និងជាប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅសាលសន្និសីទចតុមុខ។ |
| ១៨ | ២៤/០៨/១១<br>ម៉ោង ១៧ : ០០ នាទី | ប្រជុំពិភាក្សាការងារជាមួយទូតកូរ៉េខាងជើង នៅបន្ទប់ឯកឧត្តមប្រធាន ECOSOCC នៃទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៩ | ២៥/០៨/១១<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២០ | ២៦/០៨/១១<br>ម៉ោង ០៨ : ៣០ នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី ។<br>៣-បញ្ហាផ្សេងៗ ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ២១ | ៣១/០៨/១១<br>ម៉ោង ០៨ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម អនុប្រធាន និង សមាជិក-សមាជិកា ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១១

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៨/០៨/១១ | ចូលរួមក្នុងអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការជ្រើសរើសចូលក្របខណ្ឌ ការប្រឡងផ្លាស់ប្តូរប្រភេទក្របខណ្ឌ ការតម្លើងឋានន្តរសក្តិ និងការតម្លើងថ្នាក់មន្ត្រីរាជការស៊ីវិល ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់តំបន់សហគមន៍លើផ្ទៃដីទំហំ ១៥០០ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃនាមដូនសំ ស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | ២៥/០៨/១១ | ចូលរួមក្នុងអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី<br>៣-បញ្ហាផ្សេងៗ ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ៣ | ១០/០៨/១១ | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការជ្រើសរើសចូលក្របខណ្ឌ ការប្រឡងផ្លាស់ប្តូរប្រភេទក្របខណ្ឌ ការតម្លើងឋានន្តរសក្តិ និងការតម្លើងថ្នាក់មន្ត្រីរាជការស៊ីវិល ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់តំបន់សហគមន៍លើផ្ទៃដីទំហំ ១៥០០ ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃនាមដូនសំ ស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។<br>៣-បញ្ហាផ្សេងៗ ។ |

## ឯកឧត្តម ខិន រីវៈ សមាជិក

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៨/០៨/១១ | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសលទ្ធផលបណ្តោះអាសន្ននៃជំរឿនសហគ្រាសឆ្នាំ២០១១ ដែលរៀបចំដោយក្រសួងផែនការ នៅសណ្ឋាគារកាំបូឌីយ៉ាណា។ |

## ឯកឧត្តម ឡុង ឈាង សមាជិក

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១០/០៨/១១ | ចូលរួមប្រជុំពិភាក្សាឆ្លងសេចក្តីព្រាងរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារប្រចាំខែកក្កដា ឆ្នាំ២០១១ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |

## ឯកឧត្តម ឡូញ ឃៃ និង ឯកឧត្តម ខិន រីវៈ សមាជិក

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ២៣/០៨/១១ | ចូលរួមកិច្ចប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងកិច្ចព្រមព្រៀងថ្មីរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមស្តីពីការជំរុញនិងការការពារវិនិយោគ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | Ék]tþm Km sYsMNaLþn | អនុប្រធាន គ.ស.វ. |
| និពន្ធនាយក ៖ | Ék]tþm gan RtN | អគ្គលេខាធិការ គ.ស.វ. |
| និពន្ធអក្ខបទ ៖ | Ék]tþm ÉGg rtnÑ | អគ្គលេខាធិការរង គ.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច៖ | Ék]tþm mm saT | សមាជិកបម្រុង គ.ស.វ. |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | elak sy vsa | ប្រធានការិយាល័យ គ.ស.វ. |
| យកព័ត៌មាន និងថតរូប ៖ | elak ehg sP3bPa | ប្រធានការិយាល័យ គ.ស.វ. |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | elak Ek Etra | ជំនួយការទេសរដ្ឋមន្ត្រីប្រធាន គ.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ៖ ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ៖ ០២៣ ២១១ ៩៤៣

E-mail: veasna@live.in